# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបន្ថែមសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរ នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការកែសំរួលសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៥៨ សសរ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសំរួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត
- យោងលិខិតលេខ ៧១០សជណ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ១:** ត្រូវបានបន្ថែមសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត ដែលមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១-លោក **ស៊ុំ ណារុន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២-លោក **ប្រាត់ សុវណ្ណារ៉ា** | អគ្គនាយករងបេតិកភ័ណ្ឌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

៣-លោក ឈុំ ប៊ុនថន ប្រធានការិយាល័យលិខិតឆ្លងដែន និងទិដ្ឋាការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៤-លោក អ៊ិន មារត្រា ប្រធានការិយាល័យធានារ៉ាប់រង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥-លោក ខឡា ខណ្ឌច័ន្ទ អនុប្រធានការិយាល័យចត្តាឡីស័ក ក្រសួងសុខាភិបាល សមាជិក ។

**ប្រការ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អគ្គស្នងការនគរបាលជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សាលាខេត្ត និងមន្ទីរទេសចរណ៍ខេត្តជាប់ព្រំដែន ដែលមានច្រកទ្វារអន្តរជាតិ និងសមាជិកដែលមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ